**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

## ផ្ញើជូន

## ក្រុមគ្រួសារនៃសពលោកជំទាវ ឧត្តមសេនីយ៍ទោ ហ៊ិន សារិន ញ៉ឹក ហួន

**ក្រុមគ្រួសារនៃសពលោកជំទាវ ឧត្តមសេនីយ៍ទោ ហ៊ិន សារិន ញ៉ឹក ហួន ជាទីស្រលាញ់រាប់អានដ៏ជ្រាលជ្រៅ !**

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា លោកជំទាវ **ឧត្តមសេនីយ៍ទោ ហ៊ិន សារិន ញ៉ឹក ហួន** បានទទួលមរណភាពនៅថ្ងៃអាទិត្យ ១៤រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង២៣:០៩នាទីយប់ ក្នុងជន្មាយុ ៧៤ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់លោកជំទាវ **ឧត្តមសេនីយ៍ទោ ហ៊ិន សារិន ញ៉ឹក ហួន** មិនត្រឹមតែជាការបាត់បង់នូវម្តាយ ម្តាយក្មេក និងជីដូនជាទីគោរពស្រលាញ់ដ៏ជ្រាលជ្រៅ និងប្រកបដោយព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់ចំពោះក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់នូវធនធានមនុស្សមួយរូបក្នុងកងយោធពលខេមរភូមិន្ទ ដែលបានចូលរួមក្នុងចលនាតស៊ូ ធ្វើពលិកម្មគ្រប់បែបយ៉ាង បូជាកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ក្នុងបុព្វហេតុរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ ចូលរួមការងារកសាង និងអភិវឌ្ឍប្រទេសជាតិ ថែរក្សាសន្តិភាព និងរួមសុខទុក្ខជាមួយប្រជាជនកម្ពុជា រហូតដល់ថ្ងៃអវសាននៃជីវិត។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយ**ក្រុមគ្រួសារ និងសាច់ញាតិនៃសព** ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់លោកជំទាវ **ឧត្តមសេនីយ៍ទោ ហ៊ិន សារិន ញ៉ឹក ហួន** សូមបានដល់ឋានបរមសុខ និងចាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ក្រុមគ្រួសារនៃសពលោកជំទាវ ឧត្តមសេនីយ៍ទោ ហ៊ិន សារិន ញ៉ឹក ហួន ទទួលនូវការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

**នាយឧត្តមសេនីយ៍ ទៀ សីហា**